ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១០៦៩.....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការរាយការណ៍ ការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនទំនិញនាំចេញ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១.-**

ទំនិញគ្រប់ប្រភេទដែលនាំចេញ ត្រូវរាយការណ៍នៅការិយាល័យគយ ឬទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ស្របតាមបញ្ញត្តិមាត្រា ១៦ នៃច្បាប់ស្តីពីគយ ។

**ប្រការ ២.-**

ប្រតិវេទន៍គយនាំចេញត្រូវបំពេញដោយប្រតិវេទករ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីបញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ ។

ឯកសារដែលភ្ជាប់ជាមួយប្រតិវេទន៍គយនាំចេញរួមមាន ៖

- វិក័យប័ត្រ និងបញ្ជីវេចខ្ចប់ទំនិញ
- លិខិតអនុញ្ញាតរបស់រដ្ឋបាលគយ និងលិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ប្រសិនបើមានការតម្រូវ ។

ប្រតិវេទន៍គយនាំចេញ អាចត្រូវដាក់ជូនរដ្ឋបាលគយមុនពេលទំនិញមកដល់ការិយាល័យគយ ដែលត្រូវធ្វើការនាំចេញ ប្រសិនបើមានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ។

**ប្រការ ៣.-**

នាយកទីចាត់ការគយ និងរដ្ឋាករអាចអនុញ្ញាតឲ្យទំនិញមួយចំនួនត្រូវបានធ្វើការប្រកាសក្នុងទម្រង់ដោយឡែកពីប្រតិវេទន៍គយនាំចេញ ។ ការអនុញ្ញាតនេះ អាចត្រូវបានផ្តល់សម្រាប់ ៖

- ទំនិញដែលមានតម្លៃទាបជាងតម្លៃអប្បបរមាមួយ ដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ
- ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដែលនាំចេញដោយឯកបុគ្គល ។

**ប្រការ ៤.-**

នៅពេលដែលអ្នកនាំចេញ ឬអ្នកតំណាងធ្វើការស្នើសុំជាលាយល័ក្ខអក្សរ រដ្ឋបាលគយ អាចអនុញ្ញាតឲ្យធ្វើការបំពេញបែបបទបញ្ចេញទំនិញពីគយនៅកន្លែងផ្សេងពីការិយាល័យគយដែលបានកំណត់ដូចជា ទីកន្លែងដែលផលិត ឬកែច្នៃទំនិញដើម្បីនាំចេញ ឬនៅតាមកណ្តាគារនានា ក្នុងគោលបំណងធានានូវសុវត្ថិភាព និងដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មស្របច្បាប់ ។

ទំនិញដែលអាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយ ឲ្យបំពេញបែបបទបញ្ចេញទំនិញពីគយនៅទីកន្លែងផ្សេងពីការិយាល័យគយដែលបានកំណត់ មានដូចខាងក្រោម ៖

- ផលិតផលប្រកបដោយគ្រោះថ្នាក់ ទំនិញងាយឆេះ ទំនិញងាយផ្ទុះ និងទំនិញឆាប់ខូច ដែលតម្រូវឲ្យមានរបៀបថែរក្សា និងស្តុកទុកពិធីជាពិសេស
- ផលិតផលកសិកម្ម
- ផលិតផលកែច្នៃសម្រេច ឬពាក់កណ្តាលសម្រេចពីឈើ
- ជ័រកៅស៊ូគ្រប់ប្រភេទ

- ផលិតផលជលផលដែលតម្រូវឲ្យមានការផ្ទុកក្នុងល័ក្ខខ័ណ្ឌពិសេស
- ផលិតផលសម្រាប់នាំចេញ ដែលផលិតដោយក្រុមហ៊ុនវិនិយោគ ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ទំនិញផ្សេងទៀត តាមការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៥.-**

ទំនិញនាំចេញទាំងអស់ ទោះជាជាប់ ឬមិនជាប់អាករក្តី រួមទាំងមធ្យោបាយដឹកជញ្ជូនទំនិញចេញពីដែនគយ ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**ប្រការ ៦.-**

នៅពេលមានការតម្រូវពីមន្ត្រីគយមានសមត្ថកិច្ច ប្រតិវេទករត្រូវផ្តល់នូវគំរូនៃទំនិញនាំចេញ សម្រាប់សំណូមពរនៃការផ្ទៀងផ្ទាត់លើដើមកំណើត លក្ខណៈ ការចាត់ថ្នាក់តាមតារាងពន្ធគយ ឬតម្លៃគិតអាករ ។ នាយកទីចាត់ការគយ និងរដ្ឋាករអាចអនុញ្ញាតឲ្យមានការលើកលែងការផ្តល់ទំនិញគម្រូតាមការតម្រូវខាងលើនេះ ។

**ប្រការ ៧.-**

រាល់មធ្យោបាយដឹកជញ្ជូន ដែលចាកចេញពីដែនគយនៃព្រះរាជាណាចក្រកម្ពុជា ទោះបីមានផ្ទុក ឬពុំមានផ្ទុកនូវទំនិញនាំចេញក្តី ត្រូវតែបំពេញទម្រង់បែបបទគយ ដោយត្រូវដាក់ជូនរដ្ឋបាលគយនូវប្រតិវេទន៍គយនាំចេញ និងឯកសារភ្ជាប់ដូចជា ៖

- និវេទនប័ណ្ណ
- អញ្ញត្តិប័ណ្ណទំនិញ
- ឈ្មោះអ្នកទទួលខុសត្រូវលើមធ្យោបាយដឹកជញ្ជូន ។

បន្ទាប់ពីទម្រង់បែបបទគយត្រូវបានបំពេញរួច រដ្ឋបាលគយត្រូវអនុញ្ញាតឲ្យយកទំនិញទាំងអស់ដែលត្រូវនាំចេញ ដើម្បីនាំចេញពីព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង/

ហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៩
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ